# ឯកសារទស្សនទាន
## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី
## «ភារកិច្ចរបស់អង្គការ សមាគម កំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល»

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ១២:០០ថ្ងៃត្រង់

ទីកន្លែង ៖ បញ្ជាក់ជូនពេលក្រោយ (រាជធានីភ្នំពេញ)

### ១. បរិបទ

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើកាលពីថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៥។ ចាប់តាំងពីច្បាប់នេះចូលជាធរមាន អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានធ្វើការងារយ៉ាងសកម្មក្នុងការសម្របសម្រួល និងផ្សព្វផ្សាយច្បាប់នេះ រួមទាំងច្បាប់ដែលពាក់ព័ន្ធផ្សេងទៀតដល់អង្គការសង្គមស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីឱ្យពួកគេមានសមត្ថភាពពេញលេញក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់របស់ច្បាប់។ លើសពីនេះ ចាប់តាំងពីឆ្នាំ២០១៩ អង្គការ គ.ស.ក រួមជាមួយអង្គការសមាជិក និងអង្គការដៃគូមួយចំនួនផ្សេងទៀត ក៏បានចូលរួមយ៉ាងសកម្មក្នុងដំណើរការពិភាក្សាអំពីលទ្ធភាព និងសំណើរធ្វើវិសោធនកម្មច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាមួយក្រុមការងាររាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃផងដែរ។

បើទោះបីជា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានចូលជាធរមានអស់រយៈពេលប្រមាណជិត ១០ឆ្នាំមកហើយក្តី ប៉ុន្តែ ការយល់ដឹងពីច្បាប់នេះហាក់ពុំទាន់ទូលំទូលាយនៅឡើយក្នុងចំណោមសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ជាពិសេស ការអនុវត្ត និងនីតិវិធីនៃការអនុវត្តច្បាប់នៅតែមិនទាន់មានសង្គតិភាពគ្នារវាងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលធ្វើឱ្យ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅតែជួបប្រទះនូវបញ្ហាប្រឈម និងមិនទាន់មានលទ្ធភាពពេញលេញក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលមានចែងក្នុងច្បាប់នេះនៅឡើយ។

ថ្មីៗនេះក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងលេខ១២២ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ជូនដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដោយក្រសួងមហាផ្ទៃបានរំលឹកអំពីកាតព្វកិច្ចនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។ ក្នុងនោះ រួមមាន កាតព្វកិច្ចជូនដំណឹងអំពីបច្ចុប្បន្នភាពរាល់ព័ត៌មានគណនីដែលបើកសម្រាប់ប្រតិបត្តិការ កាតព្វកិច្ចជូនដំណឹងក្នុងករណីវិសោធនកម្មលក្ខន្តិកៈ ឬមានការប្រែប្រួល ផ្លាស់ប្តូរ ទីស្នាក់ការ ផ្លាស់ប្តូរ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
23/02/2023 22/02/2028
Symbol of Trust និមិត្តសញ្ញានៃការទុកចិត្ត

តំណែងថ្នាក់ដឹកនាំ កាតព្វកិច្ចដាក់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ទៅក្រសួងមហាផ្ទៃឱ្យបានមុនដំណាច់ខែកុម្ភៈ ឆ្នាំ២០២៤ នេះ និងកាតព្វកិច្ចផ្សេងៗទៀតដូចបានកំណត់ក្នុងខ្លឹមសារនៃសេចក្តីជូនដំណឹងនោះផងដែរ។

ដូច្នេះ អង្គការ គ.ស.ក នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារច្បាប់បន្ថែម ដោយផ្តោតទៅលើការបំពេញកាតព្វកិច្ចសំខាន់ៗរបស់អង្គការ សមាគម តាមការកំណត់ដោយច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង១២:០០ថ្ងៃត្រង់ នារាជធានីភ្នំពេញ (ចំពោះទីកន្លែងក្រុមការងារ គ.ស.ក នឹងជម្រាបជូនតាមក្រោយ)។

## ២. គោលបំណង

សិក្ខាសាលាផ្សព្វផ្សាយច្បាប់ ស្តីពី ការបំពេញកាតព្វកិច្ចរបស់អង្គការ សមាគម តាមការកំណត់ដោយច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល រៀបចំឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ធ្វើបទបង្ហាញអំពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ធ្វើបទបង្ហាញអំពីកាតព្វកិច្ចសំខាន់ៗ និងនីតិវិធីដែលអង្គការ សមាគម ត្រូវបំពេញនិងអនុវត្តក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។
- ដើម្បីផ្តល់ឱកាសដល់អង្គការសមាជិកនៃអង្គការ គ.ស.ក បានលើកឡើងនូវសំណួរ ឬបញ្ហាប្រឈមមួយចំនួនទាក់ទងទៅនឹងការអនុវត្តច្បាប់នេះជូនតំណាងក្រសួងដើម្បីធ្វើការសម្រួល និងដោះស្រាយ។

## ៣. អ្នកចូលរួម

សិក្ខាសាលានេះ រំពឹងថានឹងមានអ្នកចូលរួមប្រមាណ ៥០ នាក់ ដែលជាអង្គការសមាជិករបស់អង្គការ គ.ស.ក និងអង្គការដៃគូមួយចំនួនផ្សេងទៀត។

## ៤. របៀបវារៈនៃកម្មវិធី

| ពេលវេលា | ខ្លឹមសារ | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៨:៣០-៩:០០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ៩:០០- ៩:១០ | បង្ហាញពីគោលបំណងនៃកិច្ចប្រជុំ | ក្រុមការងារ គ.ស.ក |
| ៩:១០- ៩:២០ | មតិស្វាគមន៍ដោយ គ.ស.ក | លោកស្រី **ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិអង្គការ គ.ស.ក |
| ៩:២០- ១០:២០ | បទបង្ហាញទី១ ៖ | មន្ត្រីជំនាញពីក្រសួងមហាផ្ទៃ |


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

| | | |
|---|---|---|
| | -ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល<br>-នីតិវិធីក្នុងការអនុវត្តកាតព្វកិច្ចដូចដែលមានកំណត់ក្នុងបទប្បញ្ញត្តិច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល | (បញ្ជាក់ជូនពេលក្រោយ) |
| ១០:២០- ១០:៤០ | **សម្រាកអាហារសម្រន់** | អ្នកចូលរួមទាំងអស់ |
| ១០: ៤០- ១១:៤៥ | សំណួរ និងចម្លើយ និងការលើកឡើងនូវបញ្ហាប្រឈម និងសំណូមពរជូនតំណាងក្រសួងមហាផ្ទៃ | មន្ត្រីជំនាញពីក្រសួងមហាផ្ទៃ (បញ្ជាក់ជូនពេលក្រោយ)<br>អ្នកសម្របសម្រួល៖<br>លោក **ស ម៉ូរី** ប្រធានផ្នែកច្បាប់ គោលនយោបាយ និងតស៊ូមតិ |
| ១១: ៤៥- ១២:០០ | បូកសរុប និងបិទកម្មវិធី | លោកស្រី **លុយ ឆារី**<br>ប្រធានកម្មវិធីអង្គការ គ.ស.ក |
| ១២:០០ | **ពិសាអាហារថ្ងៃត្រង់** | អ្នកចូលរួមទាំងអស់ |

**សម្គាល់៖** កិច្ចប្រជុំនេះបកប្រែជាភាសាខ្មែរ និងអង់គ្លេស។ អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈ និងពេលវេលា អាស្រ័យលើពេលវេលារបស់វាគ្មិន និងបញ្ហាផ្សេងៗ។ ឯកសារផ្សេងៗរួមទាំងរូបភាព និងខ្លឹមសារសំខាន់ៗ នឹងត្រូវបានដាក់បញ្ចូលជាសាធារណៈក្នុងគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គម តាមតំណភ្ជាប់ *http://www.ccc-cambodia.org/en/resources/event-archives* *www.facebook.com/CCCsince1990* *www.youtube.com/CCCambodia*